# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 09 PR-17/EoJ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧

## ការផ្តល់គ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ២០១៧
## លោក កូជិ កានហ្សាគិ

ថ្ងៃទី២៩ ខែមេសា រដ្ឋាភិបាលជប៉ុនបានប្រកាឈ្មោះអ្នកទទួលគ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ២០១៧ ចំនួន៤០៨០រូបដែលមានស្នាដៃដ៏ឆ្នើមសម្រាប់សង្គម ផលប្រយោជន៍សាធារណៈ ឬប្រទេសជាតិ។ ក្នុងនោះមានអ្នករស់នៅប្រទេសកម្ពុជាផងដែរ គឺ៖

ឈ្មោះ : លោក កូជិ កានហ្សាគិ

មុខងារ : អតីតប្រធានសមាគមជនជាតិជប៉ុនប្រចាំប្រទេសកម្ពុជា និងជាស្ថាបនិកនៃសហាគមន៍ផ្តល់អាហារូបករណ៍ BASSAC

គ្រឿងឥស្សរិយយស : The Order of The Rising Sun , Gold and Silver Ray

ស្នាដៃ : ជំរុញការយល់ដឹងពីគ្នាទៅវិញទៅមករវាងប្រទេសជប៉ុននិងកម្ពុជា

លោកកានហ្សាគិបានដើរតួយ៉ាងសកម្មទាំងនៅជប៉ុន និងកម្ពុជាក្នុងរយៈពេលយូរឆ្នាំ។ លោកបានចូលរួមចំណែកក្នុងការស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសកម្ពុជា ហើយក៏បានធ្វើការពង្រឹងការអប់រំ វប្បធម៌ និងបរិស្ថាននៃប្រទេសកម្ពុជា ដូចជា ការដាំដើមឈើ ការផ្តល់អាហារូបករណ៍ដល់កុមារដែលមិនមានលទ្ធភាពទៅសាលារៀនដោយសារស្ថានភាពសេដ្ឋកិច្ចគ្រួសារ និងការជួយសាងសង់សាលារៀន តាមរយៈសកម្មភាព Lions Club ផងដែរ ។

ពិធីប្រគល់គ្រឿងឥស្សរិយយសនឹងត្រូវប្រារព្ធឡើងនៅពេលវេលាសមស្របនាថ្ងៃខាងមុខ។

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162; Email: info.jpn@pp.mofa.go.jp; Official Website: www.kh.emb-japan.go.jp*